# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៧២ ប្រក កសក ៨

## ប្រកាស

## ស្តីពី

## ការប្តូរឈ្មោះការិយាល័យកសិកម្មស្រុកក្រចេះ ទៅជាការិយាល័យកសិកម្ម ស្រុកចិត្របុរី និងការបង្កើតការិយាល័យកសិកម្មក្រុងក្រចេះ ចំណុះមន្ទីរកសិកម្មខេត្តក្រចេះ

***** & *****

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសំរួលអគ្គនាយកដ្ឋាន នៃ ក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ឱ្យទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការប្តូរឈ្មោះស្រុកក្រចេះ ទៅជាស្រុកចិត្របុរី និងការបង្កើតក្រុងក្រចេះ នៃខេត្តក្រចេះ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Downloaded from http://www.khmerlaws.com

# សម្រេច

**ប្រការ ១ :** ត្រូវបានប្តូរឈ្មោះការិយាល័យកសិកម្មស្រុកក្រចេះ ទៅជាការិយាល័យកសិកម្មស្រុកចិត្របុរី នៃខេត្តក្រចេះ ។

**ប្រការ ២ :** ត្រូវបានបង្កើតការិយាល័យកសិកម្មក្រុងក្រចេះ ចំណុះឱ្យមន្ទីរកសិកម្មខេត្តក្រចេះ ។

**ប្រការ ៣ :** ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ ត្រូវទទួលបន្ទុករៀបចំមន្ត្រីកសិកម្ម ដែលមានស្រាប់ ឱ្យទៅបម្រើការងារនៅការិយាល័យកសិកម្មក្រុងក្រចេះ ។

**ប្រការ ៤ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

ចាន់ សារុន

<u>កន្លែងទទួល :</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តក្រចេះ
- សាលាស្រុកចិត្របុរី
- សាលាក្រុងក្រចេះ
- មន្ទីរកសិកម្មរាជធានី-ខេត្ត
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com